ក្រសួងយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា
Ministry of Justice of Cambodia
Website : www.moj.gov.kh

# ច្បាប់
# ស្តីពី
# វិសោធនកម្មច្បាប់ស្តីពី ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
# ២០១៩

ឯកសារច្បាប់ បទប្បញ្ញត្តិ និង រាជកិច្ច គាំទ្រដោយគេហទំព័រភក្តីឡដ៏
Laws and Royal Gazette Supported by www.pheakdeylaw.com

# ព្រះរាជក្រម

## យើង

នស/រកម/០១១៩/០០៣

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្ រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៣១៨/០០៥ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មមាត្រា២៦ មាត្រា២៧ថ្មី មាត្រា២៨ មាត្រា៣១ និងមាត្រា៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំរដ្ឋសភាលើកទី១ នីតិកាលទី៦ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី១១ ខែមករា ឆ្នាំ២០១៩ នាសម័យប្រជុំពេញអង្គលើកទី២ នីតិកាលទី៤ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ១៩៩/០០២/២០១៩ កបធ.ច ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០១៩ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ៖



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

# ច្បាប់
## ស្តីពី
## វិសោធនកម្មច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ROYAUME DU CAMBODGE
LE MINISTERE DU PALAIS ROYAL



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

**មាត្រាមួយ.-**

ច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៨ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០០៨ និងច្បាប់ស្ដីពីវិសោធនកម្មច្បាប់ស្ដីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១០១៧/០១៣ ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១៧ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ ៖

-ជំពូកទី៣ (អំពីថវិកា) និងជំពូកទី៥ (អំពីអន្តរប្បញ្ញត្តិ) ត្រូវលុបចោល

-ជំពូកទី៤ ត្រូវបានកែប្រែមកជា ជំពូកទី៣ ថ្មី (អំពីទោសប្បញ្ញត្តិ)

- ជំពូកទី៦ ត្រូវបានកែប្រែមកជា ជំពូកទី៤ ថ្មី (អំពីអវសានប្បញ្ញត្តិ)

-មាត្រា ១១ មាត្រា ៨៥ មាត្រា ៨៦ មាត្រា ៨៧ និងមាត្រា ៨៨ ត្រូវលុបចោល

-មាត្រា៣ មាត្រា ១០ មាត្រា១២ មាត្រា១៣ មាត្រា១៣(ស្ទួន) មាត្រា១៧ មាត្រា២៩ មាត្រា៣០ មាត្រា៤៤ មាត្រា៤៦ មាត្រា៥៥ មាត្រា៥៧ មាត្រា៥៨ និងមាត្រាទាំងឡាយចាប់ពីជំពូកទី៤ ដល់ជំពូកទី៦ ត្រូវបានធ្វើវិសោធនកម្មដូចខាងក្រោម ៖

**មាត្រា ៣.- ថ្មី**

បទប្បញ្ញត្តិដូចមានចែងនៅក្នុងមាត្រា១៨ថ្មី នៃច្បាប់ស្ដីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវយកមកអនុវត្តសម្រាប់កំណត់ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗ។

**មាត្រា ១០.- ថ្មី**

ការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវអនុវត្តតាមច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**មាត្រា ១១.- ថ្មី (មាត្រា ១២ ចាស់)**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំតាក់តែងបទបញ្ជា និងនីតិវិធីដែលទាក់ទងទៅនឹងការគ្រប់គ្រងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដោយអនុលោមទៅតាមគោលការណ៍នៃច្បាប់នេះ និងច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

មាត្រា ១២.- ថ្មី

ក. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវអនុវត្តតាមប្រព័ន្ធបោះឆ្នោតសមាមាត្រ ដោយត្រូវបែងចែកអាសនៈតាមរូបមន្តមធ្យមភាគខ្ពស់បំផុត ដែលផ្អែកលើចំនួនអាសនៈ និងលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌល តាមជំហានទាំងឡាយដូចខាងក្រោម៖

**ជំហានទី១** ៖ កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយទទួលបានអាសនៈមួយ ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបមកចែកនឹងចំនួនអាសនៈសរុបរបស់ក្រុមប្រឹក្សា តាមរូបមន្តដូចខាងក្រោម៖

$$\text{ក}_{\text{ត}} = \frac{\text{ស}_{\text{ស}}}{\text{អ}_{\text{ស}}}$$

ក្នុងនោះ ៖

- $\text{ក}_{\text{ត}}$ ៖ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់ ២ខ្ទង់ក្រោយក្បៀស។
- $\text{ស}_{\text{ស}}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។
- $\text{អ}_{\text{ស}}$ ៖ តាងឱ្យចំនួនអាសនៈសរុបនៅក្នុងក្រុមប្រឹក្សា។

**ជំហានទី២** ៖ កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗ បានទទួលនៅក្នុងក្រុមប្រឹក្សា។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ៖

$$\text{អ}_{\text{ឆ}} = \frac{\text{ស}_{\text{ប}}}{\text{ក}_{\text{ត}}}$$

ក្នុងនោះ ៖

- $\text{អ}_{\text{ឆ}}$ ៖ ជាផលចែកដោយមិនគិតសំណល់ចែកតាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗមានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយនៅក្នុងជំហានទី៣។
- $\text{ស}_{\text{ប}}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។
- $\text{ក}_{\text{ត}}$ ៖ តាងឱ្យកូតាដែលបានកំណត់នៅក្នុងជំហានទី១។

បន្ទាប់ពីគណនាគ្រប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងជំហានទី ២ ហើយប្រសិនគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង។



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី៣។

**ជំហានទី៣** ៖ អាសនៈដែលនៅសល់ត្រូវបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលមានសិទ្ធិទទួលបាននៅក្នុងក្រុមប្រឹក្សា ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត។

រូបមន្តដូចខាងក្រោម ត្រូវអនុវត្តជាច់ដោយឡែកពីគ្នាសម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលបានចូលរួមបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ធ}+១}$$

ក្នុងនោះ ៖

- $ម_{ធ}$ ៖ តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- $ស_{ប}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។
- $អ_{ធ}$ ៖ តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។

ក្នុងករណីនៅសល់អាសនៈចំនួនមួយដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្តក្នុងជំហានទី៣ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត។

ក្នុងករណីនៅសល់អាសនៈច្រើនជាងមួយដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួនមួយត្រូវបែងចែកទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាដែលមានមធ្យមភាគខ្ពស់បំផុត។ បន្ទាប់មកត្រូវអនុវត្តតាមរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $អ_{ធ}$ ចំនួន ១ ចំពោះបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានទទួលអាសនៈចំនួនមួយក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះអាសនៈចំនួនមួយ ត្រូវផ្តល់ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុតក្នុងការអនុវត្តរូបមន្តលើកទីពីរ។ ក្នុងករណីនៅសល់អាសនៈត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកម្តងមួយអាសនៈជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់។

ខ. ការប្រកាសបេក្ខជនជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សា ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀងដូចមានចែងក្នុងមាត្រា ២១ នៃច្បាប់នេះ។

គ. ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពសមាជិកក្រុមប្រឹក្សា បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះ ត្រូវបានប្រកាសថាជាប់ឆ្នោតជាសមាជិកក្រុមប្រឹក្សារបស់សាមីគណបក្សនយោបាយ។

ឃ. ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុដូចមានចែងក្នុងចំណុច គ នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនយោបាយនោះឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជន ក្នុងរយៈពេលដប់បួន (១៤) ថ្ងៃ ក្រោយពីទទួលបានសំណើ។



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥ មាត្រា១៦ មាត្រា១៧ថ្មី មាត្រា១៨ មាត្រា២០ មាត្រា២២ ដល់មាត្រា២៦ នៃច្បាប់នេះ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាកំណត់ខាងលើ ឬមិនបានកែលម្អការខ្វះខាត ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ។

ខ. ក្នុងករណីគណបក្សនយោបាយណាមួយបោះបង់ចោលអាសនៈដែលខ្លួនទទួលបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបែងចែកអាសនៈដែលបោះបង់ចោលនោះទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលមានអាសនៈនៅក្នុងក្រុមប្រឹក្សា ក្នុងអំឡុងពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ ដោយធ្វើប្រមាណវិធីតាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី១** ៖ កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ តាមរូបមន្តដូចខាងក្រោម ៖

$$\text{ក'}_{\text{ន}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}}$$

ក្នុងនោះ ៖

- **ក'ន** ៖ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់២ខ្ទង់ក្រោយក្បៀស។
- **ស'ស** ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសេរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានទទួលអាសនៈក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសេរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានបោះបង់ចោលអាសនៈនៅក្នុងក្រុមប្រឹក្សា។
- **អ'ប** ៖ តាងឱ្យចំនួនអាសនៈដែលបានបោះបង់ចោលនៅក្នុងក្រុមប្រឹក្សា។

**ជំហានទី២** ៖ កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗបានទទួល តាមរូបមន្តដូចខាងក្រោម ៖

$$\text{អ'}_{\text{ធ}} = \frac{\text{សប}}{\text{ក'}_{\text{ន}}}$$

ក្នុងនោះ ៖

- **អ'ធ** ៖ តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួលអាសនៈក្រោយធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី៣។
- **សប** ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសេរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយ



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

- $ក'_{ឆ}$ ៖ តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១។

បន្ទាប់ពីបានធ្វើការគណនាក្នុងជំហានទី២ សម្រាប់បញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលទទួលបានអាសនៈក្នុងក្រុមប្រឹក្សា លើកលែងតែបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់បោលអាសនៈក្នុងក្រុមប្រឹក្សា ក្នុងករណីគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង។

ក្នុងករណីគណនាក្នុងជំហានទី២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី៣។

**ជំហានទី៣** ៖ អាសនៈដែលនៅសល់ត្រូវបានបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម ៖

$$ម'_{ឆ} = \frac{ស_{ឆ}}{អ'_{ឆ}+១}$$

ក្នុងនោះ ៖

- $ម'_{ឆ}$ ៖ តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- $ស_{ឆ}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយក្នុងក្រុមប្រឹក្សា។
- $អ'_{ឆ}$ ៖ តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។

វិធីសាស្រ្តដូចមានចែងក្នុងវាក្យខ័ណ្ឌទី៩ និងទី១០ ចំណុច **ក** នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី៣ និងការគណនាជាបន្តបន្ទាប់ទៀត។

ខ. ក្នុងករណីគណនាតាមរូបមន្តខាងលើ មានលទ្ធផលស្មើគ្នារវាងបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយចំនួន ដែលមិនអាចកំណត់ឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយបានទទួលអាសនៈដែលត្រូវបែងចែក គណៈកម្មការរាជធានី ឬគណៈកម្មការខេត្តរៀបចំការបោះឆ្នោត ត្រូវអនុវត្តវិធីចាប់ឆ្នោតដើម្បីកំណត់យកបញ្ជីបេក្ខជននៃគណបក្សនយោបាយឈ្នះឆ្នោត។

វិធីចាប់ឆ្នោតត្រូវដំណើរការតាមនីតិវិធីដែលកំណត់ដោយបទបញ្ជារបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

គ. ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធីដូចមានចែងក្នុងចំណុច **ឃ** នៃច្បាប់នេះ។

ឌ. ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច **ក** នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗជាបន្តបន្ទាប់។

ឃ. មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើរបាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយដែលចូលរួមនូវចំនួនសន្លឹកឆ្នោតសរុបដែលប្រើប្រាស់សម្រាប់បោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនីមួយៗ ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាតាមប្រភេទនោះ និងចំនួនសន្លឹកឆ្នោតដែលនៅសល់តាមប្រភេទនោះ។



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

**មាត្រា ១៣.–ថ្មី**

ក្នុងអាណត្តិនៃក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ប្រសិនបើមានគណបក្សនយោបាយណាមួយប្រកាសបោះបង់ចោលអាសនៈ ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬត្រូវបានរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងសមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ទាំងអស់នៃគណបក្សនយោបាយនោះលែងមានសុពលភាព និងលែងមានគុណសម្បត្តិតទៅទៀតហើយ។ ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបែងចែកអាសនៈដែលនៅទំនេរនោះ ទៅឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយផ្សេងទៀតដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ក្នុងអំឡុងពេលយ៉ាងយូរដប់បួន(១៤)ថ្ងៃ។

គណបក្សនយោបាយដែលបានចូលរួមក្នុងការបោះឆ្នោត អាចប្រកាសមិនទទួលយកអាសនៈរបស់គណបក្សនយោបាយណាមួយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយស្របតាមច្បាប់ស្តីពីគណបក្សនយោបាយនៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌណាមួយ ឬមួយចំនួន ដោយត្រូវធ្វើលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងអំឡុងពេលយ៉ាងយូរប្រាំ (០៥)ថ្ងៃ។

ក្នុងករណីពុំមានគណបក្សនយោបាយទទួលយកអាសនៈដែលនៅទំនេររបស់គណបក្សនយោបាយដែលប្រកាសបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់នីតិវិធីឡើងវិញ ដើម្បីសម្របសម្រួលជាមួយគណបក្សនយោបាយទាំងនោះ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ តាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី១** ៖ កំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈទៅតាមករណីដូចខាងក្រោម ៖

ទី១.ករណីដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្តីពីគណបក្សនយោបាយមកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម ៖

$$ក'_{ត} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

**ក'ត** ៖ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់២ខ្ទង់ក្រោយក្បៀស។



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

- ស'ស ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ។

- អ'ប ៖ តាងឱ្យចំនួនអាសនៈរបស់គណបក្សដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ។

ទី២.ករណីដូចមានចែងក្នុងកថាខណ្ឌទី២ នៃមាត្រានេះ ការកំណត់ចំនួនកូតាដែលតម្រូវឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយទទួលបានមួយអាសនៈ ត្រូវយកចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ មកចែកជាមួយនឹងចំនួនអាសនៈដែលនៅទំនេរនោះ តាមរូបមន្តដូចខាងក្រោម ៖

$$អ'_{ក} = \frac{ស'_{ស}}{អ'_{ប}}$$

ក្នុងនោះ ៖

- អ'ក ៖ តាងឱ្យកូតាជាផលចែកដែលត្រូវគិតដល់២ខ្ទង់ក្រោយក្បៀស។

- ស'ស ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ដកចេញនូវចំនួនសន្លឹកឆ្នោតបានការសរុបបោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ និងដកចេញចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយដែលបានប្រកាសមិនទទួលយកអាសនៈដែលនៅទំនេរ។

- អ'ប ៖ តាងឱ្យចំនួនអាសនៈរបស់គណបក្សនយោបាយដែលបោះបង់ចោលអាសនៈ ឬដែលត្រូវលុបឈ្មោះចេញពីបញ្ជីគណបក្សនយោបាយ ឬដែលត្រូវរំលាយ ស្របតាមច្បាប់ស្ដីពីគណបក្សនយោបាយ។

ជំហានទី២ ៖ កំណត់ចំនួនអាសនៈជាបឋមដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗត្រូវទទួលបាន ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបរបស់បញ្ជីបេក្ខជននៃគណបក្សនយោបាយនីមួយៗដែលទទួលបាន មកចែកនឹងកូតាដែលបានគិតក្នុងជំហានទី១ តាមរូបមន្តដូចខាងក្រោម ៖



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

$$\text{អ}'_{\text{ន}} = \frac{\text{សប}}{\text{ភ}'_{\text{ន}}}$$

ក្នុងនោះ ៖

- $\text{អ}'_{\text{ន}}$ ៖តាងឱ្យចំនួនអាសនៈដែលបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយបានទទួល។
- $\text{សប}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។
- $\text{ភ}'_{\text{ន}}$ ៖ តាងឱ្យកូតាដែលបានកំណត់ក្នុងជំហានទី១។

បន្ទាប់ពីបានធ្វើការគណនាក្នុងជំហានទី២ ក្នុងករណីគ្មានអាសនៈនៅសល់ដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង។

ក្នុងករណីគណនាក្នុងជំហានទី២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តក្នុងជំហានទី៣។

**ជំហានទី៣** ៖ អាសនៈដែលនៅសល់ត្រូវបានបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តដូចខាងក្រោម ៖

$$\text{ម}'_{\text{ន}} = \frac{\text{សប}}{\text{អ}'_{\text{ន}}+\text{១}}$$

ក្នុងនោះ ៖

- $\text{ម}'_{\text{ន}}$ ៖ តាងឱ្យមធ្យមភាគខ្ពស់បំផុត។
- $\text{សប}$ ៖ តាងឱ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។
- $\text{អ}'_{\text{ន}}$ ៖ តាងឱ្យចំនួនអាសនៈដែលបានបែងចែកឱ្យបញ្ជីបេក្ខជននៃគណបក្សនយោបាយមួយ។

វិធីសាស្ត្រដូចមានចែងក្នុងវាក្យខណ្ឌទី៩ និងទី១០ ចំណុច ក នៃមាត្រា១២ថ្មី នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី៣ និងការគណនាជាបន្តបន្ទាប់ទៀត។

ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ ទៅឱ្យគណបក្សនយោបាយណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឱ្យគណបក្សនយោបាយតាមការចាប់ឆ្នោតដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរប្រាំ(០៥)ថ្ងៃ គិតចាប់ពីបានទទួលសំណើ។ បែបបទនៃការទទួលពិនិត្យ និងការអនុម័តបេក្ខជនដែលស្នើបន្ថែមនេះ ត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១៥ មាត្រា១៦ មាត្រា១៧ថ្មី មាត្រា១៨ មាត្រា២០ មាត្រា



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

២២ ដល់មាត្រា២៦ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ឬមិនបានកែលម្អការខ្វះខាត ដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ។ ករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបែងចែកអាសនៈដែលនៅទំនេរនេះតាមបទប្បញ្ញត្តិនៃមាត្រានេះ។

**មាត្រា ១៧._ថ្មី**

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ៖

-សមាជិករដ្ឋសភា ព្រឹទ្ធសភា ក្រុមប្រឹក្សាធម្មនុញ្ញ រាជរដ្ឋាភិបាល និងថៅក្រម

-សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម

-អភិបាល អភិបាលរង រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់

-សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គណៈកម្មការរៀបចំការបោះឆ្នោត និងមន្ត្រី បុគ្គលិកបម្រើការងាររៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់

-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ នគរបាលជាតិក្នុងមុខតំណែង

-មន្ត្រីបុគ្គលិករបស់ក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់

-ជនដែលត្រូវបានតុលាការសម្រេចផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ បទមជ្ឈិមណាមួយ ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ

-ជនវិកលចរិត ឬ ជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅ ដែលមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច

-ជនដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬ ជនដែលត្រូវបានលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

-ព្រះសង្ឃ ឬ បព្វជិតសាសនា ។

**មាត្រា ២៩._ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំ និងផ្តល់សុពលភាពបញ្ជីបោះឆ្នោត ក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ(១៥)ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

បញ្ជីបោះឆ្នោតដែលត្រូវបានផ្តល់សុពលភាពរួចហើយ គឺជាបញ្ជីបោះឆ្នោតជាផ្លូវការមិនអាចកែប្រែបានឡើយ លើកលែងតែមានអ្នកបោះឆ្នោតណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតនោះទទួលមរណភាព ។

ក្នុងករណីមានសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ណាម្នាក់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតទទួលមរណភាព ក្រសួងមហាផ្ទៃត្រូវបំពេញបែបបទផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់នោះ ក្នុងរយៈពេល



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

ប្រាំពីរ(០៧)ថ្ងៃ យ៉ាងតិចមុនថ្ងៃបោះឆ្នោត ដើម្បីឱ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដាក់ជំនួសក្នុងបញ្ជីបោះឆ្នោត ។

**មាត្រា ៣០.-ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ក្នុងរយៈពេលយ៉ាងតិចដប់ប្រាំ(១៥)ថ្ងៃ មុនថ្ងៃបោះឆ្នោត នៅការិយាល័យបោះឆ្នោត និងនៅទីកន្លែងសាធារណៈណាមួយក្នុងមណ្ឌលបោះឆ្នោត តាមប្រភេទក្រុមប្រឹក្សា។

**មាត្រា ៤៤.-ថ្មី**

ការឃោសនាបោះឆ្នោត ត្រូវធ្វើឡើងនៅតាមមណ្ឌលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ នីមួយៗ ។

យុទ្ធនាការឃោសនាបោះឆ្នោត មានរយៈពេលប្រាំបី(០៨)ថ្ងៃ ហើយគ្រប់សកម្មភាពឃោសនាបោះឆ្នោតត្រូវបញ្ចប់ម្ភៃបួន (២៤)ម៉ោង មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៤៦.-ថ្មី**

បទប្បញ្ញត្តិដូចមានចែងក្នុង មាត្រា៦៨ មាត្រា៦៩ មាត្រា៧០ មាត្រា៧១ កថាខណ្ឌទី២ នៃមាត្រា៧២ មាត្រា៧៣ មាត្រា៧៤ មាត្រា៧៥ មាត្រា៧៦ មាត្រា៧៧ មាត្រា៧៨ មាត្រា៧៩ មាត្រា៨០ មាត្រា៨១ មាត្រា៨២ មាត្រា៨៣ មាត្រា៨៤ មាត្រា៨៥ មាត្រា៨៦ មាត្រា៨៧ មាត្រា៨៨ មាត្រា៨៩ មាត្រា៩០ និងមាត្រា៩១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

ដោយឡែក ចំពោះការរៀបចំក្បួនព្យុហយាត្រា ឬ ក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅក្នុងមណ្ឌលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនីមួយៗ ត្រូវកំណត់យ៉ាងច្រើនពីរ(០២)ដងក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

**មាត្រា ៥៥.-ថ្មី**

គណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួនពីរ(០២)រូប ពេញសិទ្ធិមួយ(០១)រូប និងបម្រុងមួយ(០១)រូប ដើម្បីចូលរួមសង្កេតការណ៍មើលការបោះឆ្នោតតាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ។

សិទ្ធិ តួនាទី និងលក្ខខណ្ឌផ្សេងៗ ក្នុងការស្នើសុំជាភ្នាក់ងារគណបក្សនយោបាយ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

បទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា១០ មាត្រា១១ មាត្រា១២ មាត្រា១៣ មាត្រា១៤ មាត្រា១៥ មាត្រា១៦ មាត្រា១៧ មាត្រា១៨ មាត្រា១៩ មាត្រា២០ មាត្រា២១ និងមាត្រា២២ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តក្នុងការសង្កេតការណ៍នៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

**មាត្រា ៥៧.-ថ្មី**

បទប្បញ្ញត្តិដូចមានចែងនៅក្នុង មាត្រា៩៦ មាត្រា៩៧ មាត្រា៩៨ មាត្រា៩៩ មាត្រា១០០ មាត្រា១០៤ មាត្រា១០៦ មាត្រា១០៧ មាត្រា១០៨ មាត្រា១១១ មាត្រា១១២ និងមាត្រា១១៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវបានយកមកអនុវត្តចំពោះកិច្ចដំណើរការនៃការិយាល័យបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

**មាត្រា ៥៨.-ថ្មី**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ក្នុងបទបញ្ជា និងនីតិវិធីអំពីការរៀបចំ និងការគ្រប់គ្រងការិយាល័យរាប់សន្លឹកឆ្នោត និងការរាប់សន្លឹកឆ្នោតឱ្យស្របទៅតាមច្បាប់នេះ និងស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុង មាត្រា១១៥ មាត្រា១១៦ មាត្រា១១៧ មាត្រា១១៨ មាត្រា១១៩ មាត្រា១២០ មាត្រា១២១ មាត្រា១២២ មាត្រា១២៤ មាត្រា១២៥ និងមាត្រា១៣៧ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

## ជំពូកទី៣ ថ្មី
## អំពីទោសប្បញ្ញត្តិ

**មាត្រា ៨២.-ថ្មី**

បទប្បញ្ញត្តិដូចមានចែងក្នុងជំពូកទី១០ លើកលែងតែមាត្រា១៥៥ មាត្រា១៥៦ និងមាត្រា១៦៤ នៃច្បាប់ស្ដីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវយកមកអនុវត្តចំពោះការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ។

**មាត្រា ៨៣.-ថ្មី**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី២ នៃមាត្រា៤៤ថ្មី និងមាត្រា៤៦ថ្មី នៃច្បាប់នេះ ក្នុងការឃោសនាបោះឆ្នោត ។

ក្នុងករណីនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពីប្រាំលាន(៥.០០០.០០០)រៀល ដល់ដប់លាន (១០.០០០.០០០)រៀល និង/ឬ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេលប្រាំ(០៥)ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនដែលប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

## ជំពូកទី៤ ថ្មី
## អវសានប្បញ្ញត្តិ

**មាត្រា ៨៤.-ថ្មី (មាត្រា ៩១ ចាស់)**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងច្បាប់នេះត្រូវទុកជានិរាករណ៍។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com

មាត្រា ៩៥.- ថ្មី (មាត្រា ៩២ ចាស់)

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់។

**មាត្រាពីរ.-**

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

ថ្ងៃ *ព្រហស្បតិ៍ ៥រោជ* ខែ *បុស្ស* ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១៩

*នស. ០១១៩.០០៣*

*នរោត្តម សីហមុនី*

**នរោត្តម សីហមុនី**

បានយកសេចក្ដីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ
សូមឡាយព្រះហស្ថលេខា
**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**

**កិត្តិនីតិកោសលបណ្ឌិត ប៊ិន ឈិន**



www.moj.gov.kh Laws and Royal Gazzette Supported by www.pheakdeylaw.com